**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**សូមគោរពជូន**

**ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នាយទាហាន នាយទាហានរង ពលទាហាន នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែល **ឯកឧត្តម** ត្រូវបានសមាជិក សមាជិកា នៃព្រឹទ្ធសភាបោះឆ្នោតជូន **ឯកឧត្តម** ជាអនុប្រធានទី១ នៃព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាចាប់ពីថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥ តទៅ។

ការបោះឆ្នោតជ្រើសរើស **ឯកឧត្តម** ជាអនុប្រធានទី១ នាពេលនេះ ពិតជាសក្តិសមទៅនឹងសមត្ថភាព និងភាពជាអ្នកដឹកនាំដែលបានធ្វើពលីកម្មបូជាកម្លាំងកាយ-ចិត្ត ដើម្បីបម្រើឧត្តមប្រយោជន៍ជាតិ និងប្រជាជន ហើយខ្ញុំមានជំនឿយ៉ាងមុតមាំថា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **ឯកឧត្តម** ស្ថាប័នព្រឹទ្ធសភានឹងបន្តដំណើរការដោយរលូនទទួលបានជោគជ័យថ្មីៗ ថែមទៀត ដើម្បីរួមចំណែកក្នុងការពង្រឹងនីតិរដ្ឋ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ ខ្ញុំសូមប្រសិទ្ធិពរជូន **ឯកឧត្តម** និង **លោកជំទាវ** ព្រមទាំងក្រុមគ្រួសារ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**